# ឯកសារសង្ខេបអំពីដៃគូអនុវត្តជាយុទ្ធសាស្ត្រ
# ផ្នែកពិការភាព

## សង្ខេបគម្រោង

យូនីសេហ្វប្រចាំកម្ពុជា អនុវត្តគម្រោងមួយក្នុងក្របខណ្ឌនៃកម្មវិធី ACCESS 2 ដែលមានគោលបំណងចូលរួមកសាងសមត្ថភាពថ្នាក់ជាតិ ដើម្បីពង្រឹងយន្តការកំណត់អត្តសញ្ញាណកម្មតាំងពីដំបូង និងធានាលទ្ធភាពប្រកបដោយគុណភាពក្នុងការទទួលបានសេវាសង្គមដ៏ចាំបាច់សម្រាប់ជនមានពិការភាពនៅកម្ពុជា។ គម្រោងនេះផ្តោតលើកិច្ចអន្តរាគមន៍ពហុវិស័យគ្រប់ជ្រុងជ្រោយនៅក្នុងចំណោមវិស័យសុខាភិបាល អប់រំ កិច្ចគាំពារសង្គម និងអនាម័យ ទឹកស្អាត (WASH) ដោយមានការយកចិត្តទុកដាក់ជាពិសេសចំពោះខេត្តសៀមរាប និងខេត្តរតនគិរី។

## លទ្ធផលរំពឹងទុករបស់គម្រោង

- ការបង្កើនការប្រើប្រាស់ទិន្នន័យពិការភាពសម្រាប់ការរៀបចំផែនការថវិកា និងការពិនិត្យតាមដានដោយស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងវិស័យកិច្ចគាំពារសង្គម អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ និងសង្គមកិច្ច។
- ការពង្រឹងយន្តការកំណត់អត្តសញ្ញាណ និងបញ្ជូនទៅរកសេវាសង្គមកិច្ច និងកម្មវិធីកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាព ដូចមានចែងនៅក្នុងបទដ្ឋានជាតិ។
- ការពង្រឹងសមត្ថភាពសហគមន៍ដើម្បីគាំទ្រ និងទាមទារសេវាសង្គមកិច្ចសម្រាប់ជនមានពិការភាព។

## សកម្មភាពសំខាន់ៗ

- បង្កើនសមត្ថភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) ចំពោះការកំណត់អត្តសញ្ញាណពិការភាព និងអន្តរប្រតិបត្តិការទិន្នន័យ
- ពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសំខាន់ៗពាក់ព័ន្ធនឹងការងារសង្គមកិច្ច ចំពោះការរៀបចំផែនការថវិកាសម្រាប់សេវាប្រកបដោយបរិយាបន្នពិការភាព

- ធ្វើឱ្យប្រសើរឡើងនូវសេវាកិច្ចការពារកុមារសម្រាប់កុមារមានពិការភាព រួមទាំងការបណ្តុះបណ្តាល ការងារសេវាសង្គម និងការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដារ (SOPs) ស្តីពីកិច្ចការពារកុមារ
- ពង្រឹងបទដ្ឋាន និងគោលការណ៍ណែនាំការរៀបចំបរិក្ខារផ្នែកអនាម័យ ទឹកស្អាត (WASH) ឱ្យមានបរិយាបន្នពិការភាព
- បង្កើនការយល់ដឹងជាសាធារណៈ និងការទទួលបានចំណេះដឹងអំពីសិទ្ធិជនមានពិការភាព តាមរយៈទម្រង់អនឡាញ និងជួបផ្ទាល់។

## អ្នកទទួលផល

អ្នកទទួលផលដោយផ្ទាល់៖ មន្ត្រីរដ្ឋាភិបាលសំខាន់ៗ បុគ្គលិកសង្គម និងក្រុមប្រឹក្សាសកម្មភាពខេត្ត (P-DACs) នៃខេត្តគោលដៅ។

អ្នកទទួលផលដោយប្រយោល៖ ជនមានពិការភាពនៅខេត្តសៀមរាប និងខេត្តរតនគិរី រួមទាំងកុមារ ដែលនឹងមានលទ្ធភាពកាន់តែល្អប្រសើរក្នុងការទទួលបានបរិក្ខារ WASH សេវាសង្គមកិច្ច និងកម្មវិធីកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្ន។

## តំបន់គោលដៅ

ខេត្តសៀមរាប ខេត្តរតនគិរី ខេត្តកំពង់ចាម និងខេត្តកំពង់ស្ពឺ

## ដៃគូអនុវត្តគម្រោង

ដៃគូសំខាន់ៗ រួមមាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលរាជធានីខេត្ត និងវិទ្យាស្ថានជាតិសង្គមកិច្ច។

## រយៈពេលអនុវត្តគម្រោង

ខែមីនា ឆ្នាំ២០២៤ ដល់ខែកុម្ភៈ ឆ្នាំ២០២៨

## ព័ត៌មានទំនាក់ទំនង

| | |
|---|---|
| យូនីសេហ្វប្រចាំកម្ពុជា<br>បណ្ឌិត Anirban Chatterjee<br>នាយករងផ្នែកកម្មវិធី<br>ទូរស័ព្ទ៖ (៨៥៥) ៦១ ៥៥៥ ៤៩៩<br>អ៊ីម៉ែល៖ achatterjee@unicef.org | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ vivath.chou@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមេសា ឆ្នាំ២០២៤